ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ : ២០ ក.យ.ពសរ./២០

# សេចក្តីសម្រេច
## ស្តីពី
## ការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំក្រសួងយុត្តិធម៌
## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៧ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរដ្ឋលេខាធិការនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាននៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៨ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងអនុរដ្ឋលេខាធិការនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាននៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩៧១ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៨
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២០/២៤៩ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤២០/៤៧៧ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥២០/៥៥៤ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២០
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២០/១១៦៩ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២០
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២០/១១៧០ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២០
- បានឃើញអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីតួនាទី និងភារកិច្ចរបស់រដ្ឋលេខាធិការប្រចាំការ
- បានឃើញអនុក្រឹត្យលេខ ១១៩ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីតួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់រដ្ឋមន្ត្រីស្តីទី



មហាវិថីសម្តេចសុធារស.ខ័ណ្ឌដូនពេញ.រាជធានីភ្នំពេញ ទូរស័ព្ទ : 023 216 322, 023 217 841, 023 212 693

- បានឃើញសេចក្តីសម្រេចលេខ ៣៨ សសរ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០២០ ស្តីពីការចាត់តាំងរដ្ឋលេខាធិការប្រចាំការនៃក្រសួងយុត្តិធម៌
- យោងតាមការចាំបាច់របស់ក្រសួងយុត្តិធម៌

## សម្រេច

**ប្រការ១ ..**

បែងចែក និងប្រគល់ភារកិច្ចជូនរដ្ឋមន្ត្រី រដ្ឋលេខាធិការប្រចាំការ រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការនៃក្រសួងយុត្តិធម៌ សំដៅជានាការដឹកនាំក្រសួងយុត្តិធម៌ឱ្យមានដំណើរការប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព និងមានការទទួលខុសត្រូវខ្ពស់ ស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា ដែលការបែងចែក និងការប្រគល់ភារកិច្ចនេះមានកំណត់នៅក្នុងប្រការបន្តបន្ទាប់ដូចខាងក្រោម។

**ប្រការ២ ..**

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជាប្រធានស្ថាប័នទទួលបន្ទុកដឹកនាំគ្រប់គ្រងការងាររួមទាំងអស់របស់ក្រសួងយុត្តិធម៌ និងវិស័យយុត្តិធម៌, ទទួលបន្ទុកដឹកនាំការងាររួមទាក់ទងនឹងការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងទទួលបន្ទុកដឹកនាំ ត្រួតពិនិត្យ និងតាមដានការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងបទបញ្ជារបស់រាជរដ្ឋាភិបាលដែលមានការពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ក្រសួងយុត្តិធម៌ និងទទួលបន្ទុកផ្ទាល់លើការងារចាត់តាំង ការងារគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួងយុត្តិធម៌ និងការងារសវនកម្មផ្ទៃក្នុង។

**ប្រការ៣ ..**

បែងចែក និងប្រគល់ភារកិច្ចជូន រដ្ឋលេខាធិការប្រចាំការ និងរដ្ឋលេខាធិការ ដើម្បីជួយការងាររដ្ឋមន្ត្រីតាមវិស័យ និង/ឬ តាមអង្គភាពចំណុះ និងអមក្រសួងយុត្តិធម៌ ដូចខាងក្រោម៖

១- លោកជំទាវ **ចាន់ សុទ្ធាវី** រដ្ឋលេខាធិការប្រចាំការ មានភារកិច្ចដូចខាងក្រោម៖

- ជួយរដ្ឋមន្ត្រីលើការងារទូទៅប្រចាំថ្ងៃតាមការប្រគល់ភារកិច្ចរបស់រដ្ឋមន្ត្រី
- ដឹកនាំការងារប្រចាំថ្ងៃរបស់ក្រសួង ក្នុងឋានៈជារដ្ឋមន្ត្រីស្តីទី ក្នុងករណីរដ្ឋមន្ត្រីអវត្តមាន ដោយជាប់បំពេញបេសកកម្មក្រៅប្រទេស ឬដោយមានមូលហេតុចាំបាច់ផ្សេងទៀត ដូចមានកំណត់ក្នុងអនុក្រឹត្យលេខ ១១៩ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីតួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់រដ្ឋមន្ត្រីស្តីទី
- ជួយរដ្ឋមន្ត្រីលើការងាររបស់អគ្គនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី លើកលែងតែវិស័យការងារដែលបានប្រគល់ភារកិច្ចជូនរដ្ឋលេខាធិការផ្សេងទទួលបន្ទុក
- ជួយរដ្ឋមន្ត្រីលើការងាររបស់រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ព្រមទាំងអង្គភាពនានាចំណុះក្រសួងយុត្តិធម៌ ឬការងារតាមវិស័យរបស់ក្រសួងយុត្តិធម៌ តាមការប្រគល់ភារកិច្ចរបស់រដ្ឋមន្ត្រី
- ជួយរដ្ឋមន្ត្រីលើការងារពាក់ព័ន្ធនឹងយេនឌ័រ ស្ត្រី និងកុមារ
- អនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

២- ឯកឧត្តម **ព្រហ្ម សិទ្ធរ៉ា** រដ្ឋលេខាធិការ មានភារកិច្ចដូចខាងក្រោម៖

- ពិនិត្យ និងផ្តល់យោបល់ជូនរដ្ឋមន្ត្រីលើការងារសវនកម្មផ្ទៃក្នុង
- ជួយរដ្ឋមន្ត្រីលើការងារប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ ដោយមានអង្គភាពជំនាញជាសេនាធិការបច្ចេកទេស
- ជួយរដ្ឋមន្ត្រីលើការងារពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ និងការងារពាក់ព័ន្ធនឹងវត្ថុតាងរឹបអូសបានពីបទល្មើសគ្រឿងញៀន ដោយមានអង្គភាពជំនាញជាសេនាធិការបច្ចេកទេស
- អនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

៣- ឯកឧត្តម **គឹម សន្តិភាព** រដ្ឋលេខាធិការ មានភារកិច្ចដូចខាងក្រោម៖

- ជួយរដ្ឋមន្ត្រីលើការងាររបស់អគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ លើកលែងតែវិស័យការងារដែលបានប្រគល់ភារកិច្ចជូនរដ្ឋលេខាធិការផ្សេងទទួលបន្ទុក
- ជួយរដ្ឋមន្ត្រីលើការងារពាក់ព័ន្ធនឹងការលើកលែងទោស និងការបន្ធូរបន្ថយទោស
- ជួយរដ្ឋមន្ត្រីលើការងារទំនាក់ទំនងជាមួយនឹងពន្ធនាគារ
- ជួយរដ្ឋមន្ត្រីលើការងារទំនាក់ទំនងជាមួយនឹងនគរបាលយុត្តិធម៌
- ជួយរដ្ឋមន្ត្រីលើការងាររៀបចំ គ្រប់គ្រង និងការអភិវឌ្ឍគេហទំព័រ និងប្រព័ន្ធទំនាក់ទំនងសង្គមរបស់ក្រសួងយុត្តិធម៌ ព្រមទាំងចងក្រងតាមប្រព័ន្ធបច្ចេកវិទ្យានូវឯកសារច្បាប់ និងលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យយុត្តិធម៌
- អនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

៤- ឯកឧត្តម **ឡុច នរិន្ទ** រដ្ឋលេខាធិការ មានភារកិច្ចដូចខាងក្រោម៖

- ជួយរដ្ឋមន្ត្រីលើការងារអធិការកិច្ច
- ជួយរដ្ឋមន្ត្រីលើការងារពាក់ព័ន្ធនឹងអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
- អនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

៥- ឯកឧត្តម **ជីវ សុខហាក់** រដ្ឋលេខាធិការ មានភារកិច្ចដូចខាងក្រោម៖

- ជួយរដ្ឋមន្ត្រីលើការងាររបស់ក្រុមប្រឹក្សានីតិកម្ម និងយុត្តិធម៌នៃក្រសួងយុត្តិធម៌ ព្រមទាំងពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ដែលស្នើឡើងពីក្រសួង-ស្ថាប័ននានារបស់រាជរដ្ឋាភិបាល
- ជួយរដ្ឋមន្ត្រីលើការងាររបស់នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងដៃគូអភិវឌ្ឍន៍នៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍វិស័យយុត្តិធម៌
- ជួយរដ្ឋមន្ត្រីក្នុងទំនាក់ទំនងការងារពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្ម និងការរៀបចំដាក់ឱ្យដំណើរការតុលាការពាណិជ្ជកម្ម
- ជួយរដ្ឋមន្ត្រីក្នុងទំនាក់ទំនងការងារពាក់ព័ន្ធនឹងវិស័យការងារ និងការរៀបចំដាក់ឱ្យដំណើរការតុលាការការងារ

- ជួយរដ្ឋមន្ត្រីលើការងារពាក់ព័ន្ធនឹងការប្រឆាំងនឹងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ
- ជួយរដ្ឋមន្ត្រីលើការងារអាជ្ញាធរកណ្ដាលពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ និងវិស័យរដ្ឋប្បវេណី ដោយមាននាយកដ្ឋានជំនួយទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ និងបត្យាប័ននៃអគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ និងនាយកដ្ឋានជំនួយទៅវិញ-ទៅមកក្នុងវិស័យរដ្ឋប្បវេណីនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី ជាសេនាធិការបច្ចេកទេស
- ជួយរដ្ឋមន្ត្រីក្នុងទំនាក់ទំនងការងារពាក់ព័ន្ធនឹងវិស័យវិនិយោគ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

៦- ឯកឧត្តម **ខិន ម៉ាលីន** រដ្ឋលេខាធិការ មានភារកិច្ចដូចខាងក្រោម៖

- ជួយរដ្ឋមន្ត្រីលើការងាររបស់អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការ លើកលែងតែវិស័យការងារដែលបានប្រគល់ភារកិច្ចជូនរដ្ឋលេខាធិការផ្សេងទទួលបន្ទុក
- ជួយរដ្ឋមន្ត្រីលើការងារពាក់ព័ន្ធនឹងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដោយមាននាយកដ្ឋានសន្ធានកម្ម និងយុត្តិធម៌មូលដ្ឋាននៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី ជាសេនាធិការបច្ចេកទេស
- ជួយរដ្ឋមន្ត្រីលើការងារទំនាក់ទំនងជាមួយអន្តរជាតិ និងដៃគូអភិវឌ្ឍន៍ក្នុងគោលដៅការងារកែទម្រង់ច្បាប់ និងវិស័យយុត្តិធម៌ និងការងារទាក់ទងនឹងវិស័យសិទ្ធិមនុស្ស
- ជួយរដ្ឋមន្ត្រីក្នុងទំនាក់ទំនងការងារពាក់ព័ន្ធនឹងវិស័យសិទ្ធិមនុស្ស ដោយមានអង្គភាពជំនាញជាសេនាធិការបច្ចេកទេស
- ធ្វើជាសេនាធិការជូនរដ្ឋមន្ត្រីលើការងារពាក់ព័ន្ធនឹងរដ្ឋបាល ហិរញ្ញវត្ថុ និងបច្ចេកទេស សម្រាប់គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- ជួយរដ្ឋមន្ត្រីក្នុងទំនាក់ទំនងការងារពាក់ព័ន្ធនឹងវិស័យកែទម្រង់នានារបស់រាជរដ្ឋាភិបាល តាមការប្រគល់ភារកិច្ចរបស់រដ្ឋមន្ត្រី
- ជួយរដ្ឋមន្ត្រីលើការងារគម្រោងតុលាការគំរូ
- អនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

៧- ឯកឧត្តម **កេង សុម៉ារិទ្ធ** រដ្ឋលេខាធិការ មានភារកិច្ចដូចខាងក្រោម៖

- ជួយលោកជំទាវ **ចាន់ សុទ្ធារី** លើការងាររបស់អគ្គនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី
- ជួយពិនិត្យ និងផ្ដល់យោបល់ជូនរដ្ឋមន្ត្រីលើការងាររបស់រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ
- ជួយរដ្ឋមន្ត្រីលើការងារស្រាវជ្រាវ ផ្សព្វផ្សាយ និងការបណ្ដុះបណ្ដាលច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ដោយមាននាយកដ្ឋានស្រាវជ្រាវ ផ្សព្វផ្សាយ និងបណ្ដុះបណ្ដាលក្នុងវិស័យព្រហ្មទណ្ឌ ជាសេនា-ធិការបច្ចេកទេស
- ជួយរដ្ឋមន្ត្រីលើការងារស្រាវជ្រាវ ផ្សព្វផ្សាយ និងការបណ្ដុះបណ្ដាលច្បាប់ក្នុងវិស័យរដ្ឋប្បវេណី ដោយមាននាយកដ្ឋានស្រាវជ្រាវ ផ្សព្វផ្សាយ និងបណ្ដុះបណ្ដាលក្នុងវិស័យរដ្ឋប្បវេណី ជាសេនាធិការបច្ចេកទេស

- ជួយរដ្ឋមន្ត្រីលើការងារពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ដោយមានអង្គភាពជំនាញជាសេនាធិការបច្ចេកទេស
- ជួយរដ្ឋមន្ត្រីលើការងាររៀបចំ គ្រប់គ្រង និងការអភិវឌ្ឍគេហទំព័រ និងប្រព័ន្ធទំនាក់ទំនងសង្គមរបស់ក្រសួងយុត្តិធម៌ ព្រមទាំងចងក្រងតាមប្រព័ន្ធបច្ចេកវិទ្យានូវឯកសារច្បាប់ និងលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យយុត្តិធម៌
- អនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

៨- ឯកឧត្តម **សួន វិសាល** រដ្ឋលេខាធិការ មានភារកិច្ចដូចខាងក្រោម៖
- ជួយរដ្ឋមន្ត្រីលើការងាររបស់អគ្គនាយកដ្ឋានអភិវឌ្ឍន៍វិស័យយុត្តិធម៌ លើកលែងតែវិស័យការងារដែលបានប្រគល់ភារកិច្ចជូនរដ្ឋលេខាធិការផ្សេងទទួលបន្ទុក
- ជួយរដ្ឋមន្ត្រីលើការងារផ្តល់ជំនួយផ្នែកច្បាប់
- ជួយរដ្ឋមន្ត្រីលើការងារមេធាវីការពារក្តីជូនជនក្រីក្រ និងការងារក្នុងទំនាក់ទំនងជាមួយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- អនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

៩- ឯកឧត្តម **កែវ សុផល** រដ្ឋលេខាធិការ មានភារកិច្ចដូចខាងក្រោម៖
- ជួយរដ្ឋមន្ត្រីលើការងាររបស់អគ្គលេខាធិការដ្ឋាន
- ជួយរដ្ឋមន្ត្រីលើការងាររបស់នាយកដ្ឋានហិរញ្ញវត្ថុនៃសាលាជម្រះក្តីនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាលតុលាការ
- អនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

១០- ឯកឧត្តម **ឆ្វី រ៉ាស៊ី** រដ្ឋលេខាធិការ មានភារកិច្ចដូចខាងក្រោម៖
- ជួយរដ្ឋមន្ត្រីលើការងារអធិការកិច្ច
- ជួយរដ្ឋមន្ត្រីក្នុងទំនាក់ទំនងការងារពាក់ព័ន្ធនឹងវិស័យបរិស្ថាន ធនធានធម្មជាតិនិងព្រៃឈើ និងការងារប្រយុទ្ធប្រឆាំងនឹងបទល្មើសក្នុងវិស័យនេះ
- អនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

**ប្រការ៤** ..

បែងចែក និងប្រគល់ភារកិច្ចជូនអនុរដ្ឋលេខាធិការ ដើម្បីជួយការងាររដ្ឋមន្ត្រី រដ្ឋលេខាធិការប្រចាំការ និងរដ្ឋលេខាធិការ ដូចខាងក្រោម៖

១- ឯកឧត្តម **ប៉ុក ម៉ាន់នី** អនុរដ្ឋលេខាធិការ ទទួលបន្ទុកការងារដូចខាងក្រោម៖
- ជួយឯកឧត្តម **ព្រហ្ម សិទ្ធត្រា** លើការងារប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ, ការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ និងការងារពាក់ព័ន្ធនឹងវត្ថុតាងរឹបអូសបានពីបទល្មើសគ្រឿងញៀន តាមភារកិច្ចដូចមានចែងក្នុងប្រការ៣ ខាងលើ
- អនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

២- លោកជំទាវ **ខៀវ សុផានី** អនុរដ្ឋលេខាធិការ ទទួលបន្ទុកការងារដូចខាងក្រោម៖

- ជួយឯកឧត្តម **កេង សុម៉ារិទ្ធ** និងលោកជំទាវ **ចាន់ សុទ្ធាវី** លើការងាររបស់អគ្គនាយកដ្ឋានកិច្ចការរដ្ឋប្បវេណី តាមភារកិច្ចដូចមានចែងក្នុងប្រការ៣ ខាងលើ
- ជួយឯកឧត្តម **កេង សុម៉ារិទ្ធ** តាមភារកិច្ចដូចមានចែងក្នុងប្រការ៣ ខាងលើ
- អនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

៣- ឯកឧត្តម **មាស សាឡឿន** អនុរដ្ឋលេខាធិការ ទទួលបន្ទុកការងារដូចខាងក្រោម៖

- ជួយឯកឧត្តម **ឡុង នរិទ្ធ** លើការងារពាក់ព័ន្ធនឹងអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី តាមភារកិច្ចដូចមានចែងក្នុងប្រការ៣ ខាងលើ
- អនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

៤- ឯកឧត្តម **សូរ ចាន់ធី** អនុរដ្ឋលេខាធិការ ទទួលបន្ទុកការងារដូចខាងក្រោម៖

- ជួយឯកឧត្តម **គឹម សន្តិភាព** តាមភារកិច្ចដូចមានចែងក្នុងប្រការ៣ ខាងលើ
- ជួយឯកឧត្តម **ឡុង នរិទ្ធ** និងឯកឧត្តម **អ៊ូ វ៉ាស៊ី** លើការងារអធិការកិច្ច តាមភារកិច្ចដូចមានចែងក្នុងប្រការ៣ ខាងលើ
- ជួយឯកឧត្តម **ជីវ សុងហាក់** តាមភារកិច្ចដូចមានចែងក្នុងប្រការ៣ ខាងលើ
- អនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

៥- ឯកឧត្តម **ច័ន្ទ មនោ** អនុរដ្ឋលេខាធិការ ទទួលបន្ទុកការងារដូចខាងក្រោម៖

- ជួយឯកឧត្តម **ព្រហ្ម សិទ្ធត្រា** លើការងារសវនកម្មផ្ទៃក្នុង តាមភារកិច្ចដូចមានចែងក្នុងប្រការ៣ ខាងលើ
- ជួយឯកឧត្តម **ជិន ម៉ាលីន** តាមភារកិច្ចដូចមានចែងក្នុងប្រការ៣ ខាងលើ
- អនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

៦- ឯកឧត្តម **នាក់ សេរីរិន** អនុរដ្ឋលេខាធិការ ទទួលបន្ទុកការងារដូចខាងក្រោម៖

- ជួយឯកឧត្តម **ជីវ សុងហាក់** តាមភារកិច្ចដូចមានចែងក្នុងប្រការ៣ ខាងលើ
- ជួយឯកឧត្តម **ឡុង នរិទ្ធ** និងឯកឧត្តម **អ៊ូ វ៉ាស៊ី** លើការងារអធិការកិច្ច តាមភារកិច្ចដូចមានចែងក្នុងប្រការ៣ ខាងលើ
- អនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

៧- ឯកឧត្តម **សន សោភ័ណ** អនុរដ្ឋលេខាធិការ ទទួលបន្ទុកការងារដូចខាងក្រោម៖

- ជួយរដ្ឋមន្ត្រីលើការងាររបស់លេខាធិការដ្ឋាននៃគណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់
- ជួយឯកឧត្តម **ជិន ម៉ាលីន** តាមភារកិច្ចដូចមានចែងក្នុងប្រការ៣ ខាងលើ
- ជួយឯកឧត្តម **សួន វិសាល** តាមភារកិច្ចដូចមានចែងក្នុងប្រការ៣ ខាងលើ
- អនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

៨- ឯកឧត្តម **អ៊ួច សុភារិទ្ធ** អនុរដ្ឋលេខាធិការ ទទួលបន្ទុកការងារដូចខាងក្រោម៖

- ជួយឯកឧត្តម **កែវ សុផល** តាមភារកិច្ចដូចមានចែងក្នុងប្រការ៣ ខាងលើ
- អនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

៩- ឯកឧត្តម **សុន ពិសិដ្ឋ** អនុរដ្ឋលេខាធិការ ទទួលបន្ទុកការងារដូចខាងក្រោម៖

- ជួយរដ្ឋមន្ត្រីលើការងារដោះស្រាយបណ្ដឹងនានា ក្នុងក្របខណ្ឌការងារជាមួយស្ថាប័នពាក់ព័ន្ធផ្សេងៗ តាមការប្រគល់ភារកិច្ចរបស់រដ្ឋមន្ត្រី
- ជួយឯកឧត្តម **កេង សុម៉ារិទ្ធ** លើការងារប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស
- ជួយឯកឧត្តម **អ៊ូ វ៉ាស៊ី** ក្នុងទំនាក់ទំនងការងារពាក់ព័ន្ធនឹងវិស័យបរិស្ថាន ធនធានធម្មជាតិ និងព្រៃឈើ និងការងារប្រយុទ្ធប្រឆាំងនឹងបទល្មើសក្នុងវិស័យនេះ តាមភារកិច្ចដូចមានចែងក្នុងប្រការ៣ ខាងលើ
- អនុវត្តភារកិច្ចផ្សេងទៀតដែលរដ្ឋមន្ត្រីប្រគល់ជូន។

**ប្រការ៥** .-

សេចក្ដីសម្រេចលេខ ០១៥ កយ.សសរ/១៨ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៨ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦** .-

រដ្ឋលេខាធិការប្រចាំការ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ នាយកខុទ្ទកាល័យ អគ្គលេខាធិការ គ្រប់អគ្គនាយក អគ្គាធិការ និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងយុត្តិធម៌ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១០រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កើត រិទ្ធ**

**កន្លែងទទួល៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ៦
- ឯកសារ កាលប្បវត្តិ